# ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក

# របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

អរ អិម អេ (ខេមបូឌា) ម.ក

# ផ្នែកទី១ - ភាគហ៊ុនិក

**ក. រចនាសម្ព័ន្ធភាគហ៊ុនិក** (គិតចាប់ពីថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២៤)

១- ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនភាគហ៊ុន | ភាគរយ |
|---|---|---|---|---|---|
| **តិចជាង ៥%** | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១ | ១ | 0,១% |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| **ចាប់ពី ៥% ដល់ ៣០%** | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| **ចាប់ពី ៣០% ឡើងទៅ** | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ៩៩៩ | ៩៩,៩% |
| **សរុប** | | | ២ | ១០០០ | ១០០% |

២- ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនភាគហ៊ុន | ភាគរយ |
|---|---|---|---|
| **អភិបាល** | ១ | ១ | 0,១% |
| **បុគ្គលិកជាន់ខ្ពស់** | គ្មាន | គ្មាន | គ្មាន |
| **សរុប** | ១ | | 0,១% |

**ខ. សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក**

**១- សិទ្ធិរបស់ភាគហ៊ុនិក**

សិទ្ធិជាមូលដ្ឋានរបស់ម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុនរបស់យើងរួមមានជាអាទិ៍ដូចខាងក្រោម៖ សិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុន សិទ្ធិចូលរួមក្នុងការបោះឆ្នោតក្នុងអង្គប្រជុំម្ចាស់ភាគហ៊ុន និង សិទ្ធិទទួលភាគលាភ។

**២- ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្តរបស់ក្រុមហ៊ុនទៅលើការការពារសិទ្ធិរបស់ភាគហ៊ុនិក**

តាមការអនុវត្តរបស់ក្រុមហ៊ុន ដើម្បីធានាសិទ្ធិរបស់ម្ចាស់ភាគហ៊ុនមានដូចតទៅ៖

១.១ **សិទ្ធិទទួលបានព័ត៌មាន៖** ភាគទុនិកត្រូវទទួលបានព័ត៌មានត្រឹមត្រូវ និងពេញលេញ ឲ្យទាន់ពេលវេលាដែលអាចធ្វើទៅបានដោយក្រុមប្រឹក្សាភិបាលនិង/ឬក្រុមហ៊ុនតាមតម្រូវការនៃច្បាប់ជាធរមាន។ ព័ត៌មានទាំងនេះរួមមានដូចខាងក្រោម:

(ក) របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស

(ខ) ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

(គ) លទ្ធផល និងរបាយការណ៍ប្រតិបត្តិការ

(ឃ) ព័ត៌មានពាក់ព័ន្ធនឹងអភិបាល និងមន្ត្រីជាន់ខ្ពស់

១.២ **សិទ្ធិចូលរួម និងបោះឆ្នោតក្នុងការប្រជុំទូទៅរបស់ម្ចាស់ភាគហ៊ុនៈ** ដោយអនុលោមតាមមាត្រា ១៨ នៃអាជីវកម្មក្រុមហ៊ុន ភាគទុនិកដែលមានសិទ្ធិបោះឆ្នោតដូចដែលបានពិពណ៌នានៅក្នុងនេះនិងត្រូវៈ

(ក) មានសិទ្ធិស្នើបន្ថែមលើរបៀបវារៈនៃកិច្ចប្រជុំទូទៅរបស់ម្ចាស់ភាគហ៊ុន និង

(ខ) អាចបោះឆ្នោតដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងនៅក្នុងការប្រជុំទូទៅរបស់ម្ចាស់ភាគហ៊ុនទាក់ទងនឹងការតែងតាំង និងការដកហូតតំណែងអភិបាល ការបង្កើនឬបន្ថយដើមទុន និងការកែប្រែមាត្រានៃអាជីវកម្មក្រុមហ៊ុន។

១.៣ **សមធម៌នៃការប្រព្រឹត្តចំពោះម្ចាស់ភាគហ៊ុនៈ** ក្រុមហ៊ុនមានភាគហ៊ុនតែមួយប្រភេទប៉ុណ្ណោះដែលជាភាគហ៊ុនធម្មតា។ អ្នកកាន់ភាគហ៊ុនទាំងអស់គឺមានសិទ្ធិស្មើភាពគ្នា។ ដំណើរការនិងនីតិវិធីសម្រាប់ការប្រជុំទូទៅរបស់ម្ចាស់ភាគហ៊ុនត្រូវធ្វើឡើងក្រោមល័ក្ខខ័ណ្ឌដែលអនុញ្ញាតឱ្យម្ចាស់ភាគហ៊ុនទាំងអស់មានសិទ្ធិស្មើគ្នា។ សម្លេងឆ្នោតមួយនឹងភ្ជាប់ទៅនឹងចំណែកភាគហ៊ុនធម្មតានីមួយៗ។

**៣- ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច និងការអនុវត្ត**

ម្ចាស់ភាគហ៊ុនទាំងអស់នៅក្នុងក្រុមហ៊ុនរបស់យើងមានសិទ្ធិស្មើនឹងចំនួនភាគហ៊ុនរបស់ពួកគេក្នុងការបោះឆ្នោតដោយគ្មានការហាមឃាត់។ រាល់ការបំពានឬការរំលោភសិទ្ធិរបស់ខ្លួនអាចត្រូវបានលើកឡើងដោយម្ចាស់ភាគហ៊ុនស្របតាមច្បាប់ដែលអាចអនុវត្តបាន។

## គ. មហាសន្និបាតភាគហ៊ុនិក

១- និតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

មហាសន្និបាតភាគហ៊ុនិកត្រូវបកស្រាយលើមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ (" មហាសន្និបាតភាគហ៊ុនិក") និងការប្រជុំវិសាមញ្ញរបស់ម្ចាស់ភាគហ៊ុន ("មហាសន្និបាតវិសាមញ្ញរបស់ភាគហ៊ុនិក")។

ក្រុមហ៊ុនត្រូវរៀបចំមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ យ៉ាងតិចមួយដងក្នុងមួយឆ្នាំដែលនឹងត្រូវធ្វើឡើងក្នុងរយៈពេល ៦ ខែបន្ទាប់ពីចុងបញ្ចប់ឆ្នាំនីមួយៗ។ មហាសន្និបាតវិសាមញ្ញរបស់ភាគហ៊ុនិកអាចត្រូវកោះហៅគ្រប់ពេលដោយក្រុមប្រឹក្សាភិបាល ឬតាមការស្នើសុំពីភាគហ៊ុនិកដែលមានភាគហ៊ុនយ៉ាងតិច ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនទាំងអស់ដែលមានសិទ្ធិបោះឆ្នោតក្នុងអង្គប្រជុំ។

២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិក

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|---|
| ១ | ១៥ សីហា ២០២៤ | សេចក្តីសម្រេចជាលាយលក្ខ័អក្សរ | ១០០% | ពិនិត្យលើការបន្តនិងបំពេញបន្ថែមនៃកិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចី | អនុម័ត ការបន្ត និងកែប្រែបំពេញបន្ថែមនៃកិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចី |

## ឃ. ការបែងចែកភាគលាភ

១- គោលនយោបាយបែងចែកភាគលាភ

ការណែនាំខាងក្រោមត្រូវអនុវត្តចំពោះការប្រកាសភាគលាភៈ

ក. ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន (" ក្រុមប្រឹក្សាភិបាល") មានសិទ្ធិក្នុងការស្នើសុំ ផ្តល់យោបល់ និងប្រកាសភាគលាភដោយអនុលោមទៅតាមគោលការណ៍គណនេយ្យ និងកំណត់ល័ក្ខខ័ណ្ឌនៃការទូទាត់តាមប្រភេទភាគ

ហ៊ុននីមួយៗដែលមានសិទ្ធិទទួលបានភាគលាភ។

ខ. ភាគលាភ (ប្រសិនបើមាន) បង់ទៅឱ្យភាគទុនិកនឹងត្រូវអនុម័តដោយសំឡេងឆ្នោតភាគច្រើនរបស់អភិបាលទាំងអស់ដែលមានវត្តមាននៅក្នុងអង្គប្រជុំដោយអនុលោមតាមមាត្រា ៨៤ នៃអនុស្សរណៈ និងមាត្រានៃការបង្កើតក្រុមហ៊ុន

គ. ភាគលាភអាចជាភាគលាភបណ្តោះអាសន្នឬភាគលាភចុងក្រោយ

ឃ. សេចក្តីប្រកាសណាមួយដែលទាក់ទងនឹងការទូទាត់ភាគលាភត្រូវកំណត់ប្រភេទនៃភាគទុនិក និង/ឬ បុគ្គលដែលមានសិទ្ធិទទួលបានភាគលាភ ចំនួនភាគលាភក្នុងមួយភាគហ៊ុន រយៈពេលនៃការទូទាត់ និង ទម្រង់និងវិធីនៃការទូទាត់

ង. ក្រុមប្រឹក្សាភិបាលអាចកំណត់ចំនួនដើម្បីរក្សាទុកទឹកប្រាក់ដែលរកបាន ឬទទួលបាន ដោយអនុលោមតាមមាត្រា ៦៩ នៃអនុស្សរណៈ និងមាត្រានៃការបង្កើតក្រុមហ៊ុន និង

ច. ក្នុងកម្រិតនៃការអនុញ្ញាតិដោយច្បាប់ដែលអាចអនុវត្តបាន ក្រុមហ៊ុនអាចបង់ភាគលាភដោយការចែករំលែកភាគហ៊ុនជាប្រាក់ ឬទ្រព្យសម្បត្តិ។

២- ព័ត៌មានអំពីការបែងចែកភាគលាភ និងការទូទាត់គូប៉ុង ក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| ល.រ | ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែកភាគលាភលើកទី១ | ១៨ មេសា ២០២៤ | ២០ មករា ២០២៣ | ១០ មករា ២០២២ |
| ២ | កាលបរិច្ឆេទប្រកាសបែកភាគលាភលើកទី២ | ១២ មិថុនា ២០២៤ | ០៧ កុម្ភៈ ២០២៣ | ១៩ មេសា ២០២២ |
| ៣ | កាលបរិច្ឆេទប្រកាសបែកភាគលាភលើកទី៣ | ០១ កក្កដា ២០២៤ | ១០ សីហា ២០២៣ | ០២ ឧសភា ២០២២ |
| ៤ | កាលបរិច្ឆេទប្រកាសបែកភាគលាភលើកទី៤ | គ្មាន | ១៤ ធ្នូ ២០២៣ | ១៧ មិថុនា ២០២២ |
| ៥ | កាលបរិច្ឆេទប្រកាសបែកភាគលាភលើកទី៥ | គ្មាន | គ្មាន | ២២ កក្កដា ២០២២ |
| ៦ | កាលបរិច្ឆេទប្រកាសបែកភាគលាភលើកទី៦ | គ្មាន | គ្មាន | ៣០ សីហា ២០២២ |
| ៧ | កាលបរិច្ឆេទប្រកាសបែកភាគលាភលើកទី៧ | គ្មាន | គ្មាន | ១៩ កញ្ញា ២០២២ |
| ៨ | កាលបរិច្ឆេទប្រកាសបែកភាគលាភលើកទី៨ | គ្មាន | គ្មាន | ១៣ តុលា ២០២២ |
| ៩ | កាលបរិច្ឆេទប្រកាសបែកភាគលាភលើកទី៩ | គ្មាន | គ្មាន | ២៨ វិច្ឆិកា ២០២២ |
| ១០ | កាលបរិច្ឆេទប្រកាសបែកភាគលាភលើកទី១០ | គ្មាន | គ្មាន | ២២ ធ្នូ ២០២២ |

| ល.រ | ពិពណ៌នាលម្អិតអំពីការទូទាត់គូប៉ុង | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទទូទាត់គូប៉ុង | ០៩ មេសា ២០២៤ | ០៩ មេសា ២០២៣ | ០៩ មេសា ២០២២ |

## ផ្នែកទី២ - ក្រុមប្រឹក្សាភិបាល

### ក. ក្រុមប្រឹក្សាភិបាល

១- សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទតែងតាំង | កាលបរិច្ឆេទបញ្ចប់អាណត្តិមុន | កាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|---|
| ១ | លោក Kevin Robert Whitcraft | ប្រធានក្រុមប្រឹក្សាភិបាល | ២៦ កញ្ញា ២០០២ | ២៨ កក្កដា ២០២២ | ២៨ កក្កដា ២០២៥ |
| ២ | លោកThomas Arthur Whitcraft | អភិបាលមិនប្រតិបត្តិ | ២៦ កញ្ញា ២០០២ | ២៨ កក្កដា ២០២២ | ២៨ កក្កដា ២០២៥ |
| ៣ | លោក ងន សាំង | អភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិ | ២៣ មីនា ២០១៦ | ២៨ កក្កដា ២០២២ | ២៨ កក្កដា ២០២៥ |
| ៤ | លោក Ith Vichit | អភិបាលឯករាជ្យ | ២៩ កក្កដា ២០១៩ | ២៨ កក្កដា ២០២២ | ២៨ កក្កដា ២០២៥ |
| ៥ | លោក Wiedmann Apiwat Christian | អភិបាលមិនប្រតិបត្តិ | ៣១ ឧសភា ២០២៣ | | ២៨ កក្កដា ២០២៥ |

២- ជីវប្រវត្តិសង្ខេបរបស់អភិបាលនីមួយៗ

| ល.រ | ឈ្មោះ និងមុខតំណែង | បទពិសោធន៍ |
|---|---|---|
| ១ | លោក Kevin Whitcraft *ប្រធានក្រុមប្រឹក្សាភិបាល* | លោក Kevin Whitcraft បានក្លាយជានាយកផ្នែកលក់ប្រចាំតំបន់ឲ្យក្រុមហ៊ុន Rochester Midland នៅក្នុងឆ្នាំ១៩៨៥ និងបានចូលរួមជាមួយភ្នាក់ងារបរិក្ខារ និងឧស្សាហកម្ម និងអាជីវកម្មចែកចាយទូទាំងតំបន់អាស៊ីមកដល់បច្ចុប្បន្ន។ លោកបានបញ្ចប់ថ្នាក់ឧត្តមសិក្សានៅសាកលវិទ្យាល័យ American នៅទីក្រុង Washington និងនៅសាលាពាណិជ្ជកម្ម Harvard។ លោក Kevin បានបង្កើតក្រុមហ៊ុន RM Asia (HK) នៅក្នុងឆ្នាំ ១៩៨៥ និងចំណាយរយៈពេលខ្លីក្នុងការដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទូទៅនៅប្រទេសថៃ។ បទពិសោធន៍នេះបានធ្វើឲ្យលោកត្រឡប់មកក្រុមហ៊ុន RM Asia និងបង្កើតក្រុមហ៊ុនពាណិជ្ជកម្មជំជោគជ័យមួយដែលបានឈានមុខគេក្នុងការផ្គត់ផ្គង់សេវាកម្មដឹកជញ្ជូនផ្នែកពាណិជ្ជកម្មតាមនាវាដំបូងបង្អស់រវាង ប្រទេសថៃ និងកម្ពុជា។ មិនយូរប៉ុន្មាន លោកក៏បានបង្កើតក្រុមហ៊ុន អ អិម អេ ខេមបូឌា ហើយលោកបានអភិវឌ្ឍក្រុមហ៊ុននេះទៅជាអាជីវកម្មចែកចាយ លក់ និងផ្សព្វផ្សាយសេវាកម្មផ្នែកយានយន្ត និងបរិក្ខាដែលធំបំផុត នៅទីផ្សារថៃ និងកម្ពុជា។ លោក Kevin គឺជាអ្នកប្រណាំងទូកក្ដោង និងតំណាងឲ្យកីឡាករនៃក្រុមប្រណាំងទូកក្ដោងជម្រើសជាតិប្រចាំប្រទេសថៃ។ |
| ២ | លោក Thomas Arthur Whitcraft | លោក Thomas Whitcraft កាន់មុខតំណែងជាអភិបាលជាច្រើន នៅក្នុង អ អិម អេ គ្រុប និងជាស្ថាបនិកដំបូងមួយនៃក្រុមហ៊ុន RMA Asia |

| | | |
|---|---|---|
| | *អភិបាលមិនប្រតិបត្តិ* | (HK) នៅក្នុងឆ្នាំ១៩៨៥។ លោក កើតនៅទីក្រុងបាំងកក ក្នុងឆ្នាំ១៩៦២ ហើយបានបញ្ចប់ការសិក្សានៅសាលាអន្តរជាតិបាំងកក (១៩៨០) លោកបានបញ្ចប់ថ្នាក់ឧត្តមសិក្សាជំនាញរដ្ឋបាលពាណិជ្ជកម្មពីមហាវិទ្យាល័យ Southampton នៃសកលវិទ្យាល័យ Long Island N.Y. នៅក្នុងឆ្នាំ១៩៨៥។ លោក Thomas គឺជាសហប្រធានរបស់គណៈកម្មាការរៀបចំពិធនិចសម្រាប់ថ្ងៃឯករាជ្យ AMCHAM (១៩៩៧ រហូតដល់បច្ចុប្បន្ន) និងជាអនុឧត្តមសេនីយ៍ត្រីទាហានជើងទឹក ប្រចាំក្រុម Royal Varuna Yacht (២០១៣ រហូតដល់បច្ចុប្បន្ន) ព្រមទាំងជាសមាជិកនៃក្រុម Rotary ប្រចាំភូមិភាគខាងត្បូងនៃទីក្រុងបាំងកក។ លោកមានមុខតំណែងជាហេរញ្ញិកប្រចាំ Indochina Media Memorial Fund (IMMF) ចាប់ពីឆ្នាំ ២០០១ រហូតដល់ ២០០៣។ |
| ៣ | លោក ងន សាំង<br>*អភិបាលមិនប្រតិបត្តិ និងជានាយកប្រតិបត្តិ* | លោក ងន សាំង បានក្លាយជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន អ អិម អេ ខេមបូឌាចាប់តាំងពីខែធ្នូ ឆ្នាំ២០១៤ និងបច្ចុប្បន្នជាសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Comin Asia Pte. Ltd។ លោក សាំង បានចូលបម្រើការងារជាបុគ្គលិកកម្មសិក្សានៅក្នុងក្រុមហ៊ុន អ អិម អេ ខេមបូឌា នៅឆ្នាំ១៩៩៦ និងទទួលបាលការតំឡើងតំណែងជាបន្តបន្ទាប់ រហូតក្លាយជាបុគ្គលិកជាន់ខ្ពស់នៅក្នុងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ។ លោក សាំង ត្រូវបានតែងតាំងជានាយករងគ្រប់គ្រងប្រចាំប្រទេស និងនាយកហិរញ្ញវត្ថុប្រចាំក្រុមហ៊ុន អ អិម អេ ខេមបូឌា ក្នុងឆ្នាំ២០០៧។ លោកបានរួមចំនែកដល់កំណើនអាជីវកម្ម និងគាំទ្រដល់ពិពិធកម្មចាប់ពីអាជីវកម្មយានយន្ត និងបង្កើតថាមពលលើកដំបូង រហូតដល់ការផ្តល់សេវាកម្មទៅតាមតម្រូវការអតិថិជនសម្រាប់អាជីវកម្មគ្រប់ប្រភេទនៅកម្ពុជា។ លោក សាំងបានបញ្ចប់ថ្នាក់ឧត្តមសិក្សាជំនាញសេដ្ឋកិច្ចពីសលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅទីក្រុងភ្នំពេញ និងបញ្ចប់ថ្នាក់ក្រោយឧត្តមសិក្សាជំនាញពាណិជ្ជកម្មអន្តរជាតិពីវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី (AIT) នៅប្រទេសថៃ។ លោកគឺជាបុគ្គលដំបូងគេបង្អស់ពីប្រទេសកម្ពុជាដែលបានចូលរួមកម្មវិធីស្តីពីការគ្រប់គ្រងទូទៅនៃសាលាពាណិជ្ជកម្ម Harvard។ |
| ៤ | លោក Wiedmann Apiwat Christian<br>*អភិបាលមិនប្រតិបត្តិ* | លោក Wiedmann Apiwat Christian បានក្លាយជាអនុប្រធានជាន់ខ្ពស់របស់ អ អិម អេ គ្រុប និងជាប្រធានគ្រប់គ្រងផ្នែករថយន្តនៅក្នុងឆ្នាំ២០២៣។ គាត់គឺជាអ្នកមើលការគ្រប់គ្រងទាំងស្រុងរបស់ អ អិម អេ គ្រុប និងបង្រួបបង្រួមរាល់សកម្មភាពទាក់ទងនឹងរថយន្ត (នៅក្រៅប្រទេសកម្ពុជា) ដែលស្ថិតនៅក្រោមការដឹកនាំរបស់គាត់។ លោក Wiedmann Apiwat Christian គឺជាអ្នកជំនាញផ្នែករថយន្ត និងហិរញ្ញវត្ថុ ដែលបានចាប់ផ្តើមអាជីពជាមួយ AIG Private Banking និង PwC នៅប្រទេសស្វីស មុនពេលដែលចាប់ផ្តើមអាជីពជាមួយ BMW Group នៅប្រទេសអាល្លឺម៉ង់នៅក្នុងឆ្នាំ២០០១។ នៅ BMW Group គាត់បានបម្រើមុខងារជាអ្នកគ្រប់គ្រងជាន់ខ្ពស់ជាច្រើននៅក្នុងផ្នែកសាជីវកម្ម សេវាហិរញ្ញវត្ថុ និងផ្នែករថយន្តBMW ដែលភាគច្រើនកាន់មុខងារជា |

| | | |
|---|---|---|
| | | ប្រធានប្រតិបត្តិការ (COO), ប្រធានផ្នែកហិរញ្ញវត្ថុ (CFO) និង នាយកប្រតិបត្តិ (CEO) នៃក្រុមហ៊ុនរបស់BMW នៅក្នុងតំបន់ជាច្រើននៅទូទាំងពិភពលោក រួមមានប្រទេសអាល្លឺម៉ង់ ជប៉ុន អូទ្រីស ក្រិក កូរ៉េខាងត្បូង អូស្ត្រាលី និងប្រទេសថៃ។<br>លោកធ្លាប់បានបម្រើមុខងារជាប្រធានសមាគមអ្នកនាំចូលរថយន្តជប៉ុន ព្រមទាំងជាក្រុមប្រឹក្សានៃសភាពាណិជ្ជកម្មថៃអាល្លឺម៉ង់ សភាពាណិជ្ជកម្ម និងឧស្សាហកម្មអាល្លឺម៉ង់ជប៉ុន និងក្រុមប្រឹក្សាធុរកិច្ចអាស៊ានអឺរ៉ុប។<br>លោក Wiedmann Apiwat Christian បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតពីសាកលវិទ្យាល័យ Fribourg ប្រទេសស្វីស។ |
| ៥ | លោក Ith Vichit<br>*អភិបាលឯករាជ្យ* | លោក Vichit មានមុខតំណែងជាថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើននៅក្នុងប្រទេសកម្ពុជា និងនៅបរទេស ហើយមាននូវបទពិសោធន៍ទូលំទូលាយនៅក្នុងតួនាទីជាទីប្រឹក្សាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកកាន់តំណែងជា ថ្នាក់ដឹកនាំផ្សេងៗនៅក្រុមហ៊ុនពហុជាតិក្នុងតំបន់ និងក្នុងសកលទូទាំងចក្រភពអ៊ឺរ៉ុប សហរដ្ឋអាមេរិក អាស៊ីកណ្តាល អាហ្វ្រិក និងអាស៊ីអាគ្នេយ៍។ បទពិសោធន៍របស់លោក មាននៅគ្រប់វិស័យ ចាប់ពីសេវាធនាគារវិនិយោគ និងការជួញដូរទំនិញ រហូតដល់សហគ្រាសផលិតកម្ម ផលិតកម្មអាហារ និងការបើកបរយន្តហោះ។<br>លោក Vichit បានចូលរួមបង្កើតក្រុមប្រឹក្សាវិនិយោគកម្ពុជានៅឆ្នាំ ១៩៩៤ ខណៈពេលដែលលោកបានបម្រើការងារជារដ្ឋលេខាធិការដំបូងបង្អស់ឲ្យក្រុមប្រឹក្សាវិនិយោគកម្ពុជា។ លោក គឺជានាយកប្រតិបត្តិដំបូងបង្អស់នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សេដ្ឋកិច្ចប្រចាំ Madagascar និងជាប្រធាននៃក្រុមការងារយុទ្ធសាស្ត្រសេដ្ឋកិច្ចសម្រាប់នីតិកាលជាប្រធានាធិបតីរបស់ Madagascar។ តាមរយៈការចូលរួមសំខាន់របស់លោកនៅក្នុងការរៀបចំរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាអភិវឌ្ឍន៍ Rwada លោកបានចែករំលែកដល់ការក្លាយខ្លួនជាអ្នកកែទម្រង់សកលរបស់ Rwada នៅក្នុងធនាគារពិភពលោកពាក់ព័ន្ធនឹង "ការសម្រួលដល់ការធ្វើអាជីវកម្ម" ដែលបានជាប់ចំណាត់ថ្នាក់ខ្ពស់បំផុតចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១០។ នៅប្រទេសកម្ពុជា លោក Vichit បានបម្រើការងារជាទីប្រឹក្សាប្រចាំប្រទេសនៃ Axiata Group និងជាអភិបាលឯករាជ្យឲ្យក្រុមហ៊ុនបុត្រសម្ព័ន្ធ Hello និង Smart អស់រយៈពេល ៥ឆ្នាំ។ លោកបានបង្កើតនូវក្រុមហ៊ុន Apsara Rice (Cambodia) co., Ltd. និងបានក្លាយខ្លួនជាអភិបាលប្រតិបត្តិរបស់ក្រុមហ៊ុននេះផងដែរ។ ក្នុងពេលបច្ចុប្បន្ន លោក គឺជាអភិបាលឯករាជ្យរបស់ធនាគារ Phillip ឌេលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Phillip Capital ប្រចាំប្រទេសសិង្ហបុរី។ លោកគឺជាទីប្រឹក្សាជាន់ខ្ពស់ ប្រចាំ តំបន់អាស៊ីអាគ្នេយ៍ឲ្យក្រុមហ៊ុន Monitor Consulting ដែលបច្ចុប្បន្នរួមបញ្ចូលគ្នាជាមួយ Deloitte Consulting និងជាភាគហ៊ុនិក របស់កសិដ្ឋានផលិតទឹកដោះគោ Moo។ លោក Vichit បានបញ្ចប់ថ្នាក់ក្រោយឧត្តមសិក្សា ពីសកល |

| | | |
|---|---|---|
| | | វិទ្យាល័យ Harvard ដោយមានជំនាញផ្នែកគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងទីផ្សារមូលធន។ លោកបានចូលរួមកម្មវិធីបណ្តុះបណ្តាលសម្រាប់បុគ្គលិកជាន់ខ្ពស់នៅ សាលាពាណិជ្ជកម្ម Stanford។ លោកបានទទួលពានរង្វាន់ "អ្នកដឹកនាំសកលសម្រាប់ថ្ងៃស្អែក" ពីវេទិកាសេដ្ឋកិច្ចពិភពលោកនៅទីក្រុង Davos ប្រទេសស្វីស។ |

៣- ករណីអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុនផ្សេងទៀត

| ល.រ | ឈ្មោះអភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ១ | លោក Kevin Whitcraft | ១. EFG (EXPRESS FOOD GROUP) CO., LTD | ប្រធានក្រុមប្រឹក្សាភិបាល |
| | | ២. A.V.R (ASIA VEHICLE RENTAL) CO., LTD | ប្រធានក្រុមប្រឹក្សាភិបាល |
| | | ៣. NEWREST (CAMBODIA) CO., LTD | អភិបាល |
| | | ៤. COMIN KHMERE CO., LTD | ប្រធានក្រុមប្រឹក្សាភិបាល |
| | | ៥. PROPERTY CARE SERVICES (CAMBODIA) COMPANY LIMITED | អភិបាល |
| | | ៦. AMR (CAMBODIA) LTD | ប្រធានក្រុមប្រឹក្សាភិបាល |
| | | ៧. CAMBODIA INDOCHINA ASSETS CORPORATION PTE LTD. (C.I.A.L) | អភិបាល |
| | | ៨. MUSEUM VIEW CO., LTD | អភិបាល |
| | | ៩. FOOD AND BEVERAGE SOLUTIONS CO., LTD | អភិបាល |
| | | ១០. BSP FINANCE (CAMBODIA) PLC. | ប្រធានក្រុមប្រឹក្សាភិបាល |
| | | ១១. JWD ASIA LOGISTICS (CAMBODIA) CO., LTD | ប្រធានក្រុមប្រឹក្សាភិបាល |
| | | ១២. R M A AUTOMOTIVE (CAMBODIA)C., LTD | ប្រធានក្រុមប្រឹក្សាភិបាល |
| ២ | លោក Thomas Arthur Whitcraft | ១. AUTO SALES (CAMBODIA) LIMITED | ប្រធានក្រុមប្រឹក្សាភិបាល |
| | | ២. A.V.R (ASIA VEHICLE RENTAL) CO., LTD | អភិបាល |
| ៣ | លោក ងន សាំង | ១. A.V.R (ASIA VEHICLE RENTAL) CO., LTD | អភិបាល |

| | | | |
|---|---|---|---|
| | | ២. COMIN KHMERE CO., LTD | អភិបាល |
| | | ៣. PROPERTY CARE SERVICES (CAMBODIA) COMPANY LIMITED | ប្រធានក្រុមប្រឹក្សាភិបាល |
| | | ៤. JWD ASIA LOGISTICS (CAMBODIA) CO., LTD | អភិបាល |
| | | ៥. R M A AUTOMOTIVE (CAMBODIA) CO., LTD | អភិបាល |
| | | ៦. BSP FINANCE (CAMBODIA) PLC. | អភិបាល |
| ៤ | លោក Ith Vichit | ១. Forte Insurance | អភិបាលឯករាជ្យ |
| ៥ | លោក Wiedmann Apiwat Christian | គ្មាន | គ្មាន |

៤- តួនាទី ភារកិច្ច ការទទួលខុសត្រូវ និងការអនុវត្តរបស់ក្រុមប្រឹក្សាភិបាល

អនុលោមតាមមាត្រា ២៥ នៃអនុស្សរណៈ និងមាត្រានៃការបង្កើតក្រុមហ៊ុន RMAC ដោយគ្មានការលំអៀងទៅលើអំណាចណាមួយដែលបានប្រគល់ឱ្យអភិបាលក្រោមមាត្រាទាំងនេះ បានប្រកាសថាអភិបាលត្រូវតែមានអានុភាពដូចខាងក្រោម៖

ក. ចេញប័ណ្ណភាគហ៊ុនតាមកម្រិតដែលបានអនុញ្ញាតក្នុងមាត្រានេះ
ខ. ស្នើសុំទៅភាគហ៊ុនិកចំពោះការកែប្រែមាត្រាទាំងនេះ
គ. ស្នើសុំទៅភាគហ៊ុនិកនូវការបញ្ចូលកិច្ចព្រមព្រៀង ឬការរក្សារទុក ឬការ បញ្ចូលគ្នារវាងក្រុមហ៊ុន RMAC និងក្រុមហ៊ុនផ្សេងៗទៀត
ឃ. ស្នើសុំទៅភាគហ៊ុនិកនូវការលក់ទ្រព្យសម្បត្តិ ឬផ្នែកសំខាន់ៗទាំងអស់នៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន RMAC
ង. ស្នើសុំទៅភាគហ៊ុនិកនូវការរំសាយ ឬការរំលាយក្រុមហ៊ុន RMAC ស្របតាមការអនុវត្តច្បាប់និង បទបញ្ញត្តិ។
ច. តែងតាំង ដកហូត បញ្ឈប់ ឬចាត់វិធានការលើការគ្រប់គ្រងរបស់ក្រុមហ៊ុន RMAC ដោយមានការអនុម័តពីអាជ្ញាធរត្រួតពិនិត្យណាមួយដែលពាក់ព័ន្ធក្នុងករណីដែលចាំបាច់ ដើម្បីដឹកនាំនិងគ្រប់គ្រង និងកែតម្រូវសំណងរបស់ពួកគេ
ឆ. តែងតាំង ដកហូត បញ្ឈប់ ឬចាត់វិធានការលើមន្ត្រី និង លេខាធិការរបស់ក្រុមហ៊ុន RMAC ដោយមានការអនុម័តពីអាជ្ញាធរត្រួតពិនិត្យណាមួយដែលពាក់ព័ន្ធក្នុងករណីដែលចាំបាច់ ដើម្បីដឹកនាំនិងគ្រប់គ្រង និងកែតម្រូវសំណងរបស់ពួកគេ
ជ. សម្រេចលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងគំរោងអាជីវកម្មប្រចាំឆ្នាំរបស់ក្រុមហ៊ុន RMAC
ឈ. សម្រេចលើការអភិវឌ្ឍទីផ្សារ ការធ្វើទីផ្សារ និងយុទ្ធសាស្ត្របច្ចេកវិទ្យារបស់ក្រុមហ៊ុន RMAC
ញ. ចូលរួមក្នុងការចរចារ និងកិច្ចព្រមព្រៀងនានា និងដើម្បីឱ្យមានប្រសិទ្ធិភាពចំពោះការកែប្រែ ភាពខុសប្លែក ឬការដោះស្រាយការចរចាណាមួយ ឬដើម្បីអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុនៃកិច្ចព្រមព្រៀងនីមួយៗដែលបានចូលរួម
ដ. ដើម្បីផ្តល់ការធានាជំនួសឱ្យក្រុមហ៊ុន RMAC
ឋ. អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុនៃហិរញ្ញវត្ថុឆ្នាំនីមួយៗ និងស្នើសុំការបែងចែកភាគលាភទៅភាគទុនិកសម្រាប់ការអនុម័តនោះ
ឌ. ដើម្បីបើក រក្សាទុក ប្រតិបត្តិ និងបិទគណនីរបស់ក្រុមហ៊ុនជាមួយធនាគារណាមួយ
ឍ. ដើម្បីអនុម័តលើការបង្កើតការិយាល័យតំណាងសាខាក្រុមហ៊ុន បុត្រសម្ព័ន្ធ សាខាភ្នាក់ងារ និងក្រុមហ៊ុនដែល

ពាក់ព័ន្ធផ្សេងទៀត ដើម្បីធ្វើការសម្រេចចិត្តសម្រាប់ការគ្រប់គ្រងរបស់ពួកគេ និងដើម្បីបញ្ឈប់ដូចគ្នាដែលពួកគេគិតថាសម ឬបានកំណត់។

ណ.តែងតាំងភ្នាក់ងារ និងមេធាវីសម្រាប់ក្រុមហ៊ុន RMAC នៅក្នុងប្រទេសកម្ពុជា ឬនៅប្រទេសណាមួយតាមអំណាចដែលមាន (រួមទាំងអំណាចក្នុងការធ្វើប្រតិភូកម្ម) តាមអ្វីដូចដែលពួកគេគិតថាសម

ត. ធ្វើសកម្មភាពផ្សេងទៀតដែលអាចធ្វើបានស្របតាមការអនុញ្ញាតនៃច្បាប់និងបទប្បញ្ញត្តិនានានៃប្រទេសកម្ពុជា។

៥- កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១ | ១៣ កុម្ភៈ ២០២៤ | ការប្រជុំដោយផ្ទាល់មាត់<br>និង តាមរយៈការប្រជុំអនឡាញ | លោក Kevin Robert WHITCRAFT<br>លោក Thomas Arthur WHITCRAFT<br>លោក ងន សាំង<br>លោក ITH Vichit<br>លោក Wiedmann Apiwat Christian |
| ២ | ០១ មេសា ២០២៤ | ការប្រជុំដោយផ្ទាល់មាត់<br>និង តាមរយៈការប្រជុំអនឡាញ | លោក Kevin Robert WHITCRAFT<br>លោក Thomas Arthur WHITCRAFT<br>លោក ងន សាំង<br>លោក ITH Vichit<br>លោក Wiedmann Apiwat Christian |
| ៣ | ១៣ ឧសភា ២០២៤ | ការប្រជុំដោយផ្ទាល់មាត់<br>និង តាមរយៈការប្រជុំអនឡាញ | លោក Kevin Robert WHITCRAFT<br>លោក Thomas Arthur WHITCRAFT<br>លោក ងន សាំង<br>លោក ITH Vichit<br>លោក Wiedmann Apiwat Christian |
| ៤ | ២៨ សីហា ២០២៤ | ការប្រជុំដោយផ្ទាល់មាត់<br>និង តាមរយៈការប្រជុំអនឡាញ | លោក Kevin Robert WHITCRAFT<br>លោក Thomas Arthur WHITCRAFT<br>លោក ងន សាំង<br>លោក ITH Vichit<br>លោក Wiedmann Apiwat Christianey |
| ៥ | ២៧ វិច្ឆិកា ២០២៤ | ការប្រជុំដោយផ្ទាល់មាត់<br>និង តាមរយៈការប្រជុំអនឡាញ | លោក Kevin Robert WHITCRAFT<br>លោក Thomas Arthur WHITCRAFT<br>លោក ងន សាំង<br>លោក ITH Vichit<br>លោក Wiedmann Apiwat Christian |

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១- រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

#### ១-១ គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក ITH Vichit | ប្រធានគណៈកម្មាធិការ | ០៨ តុលា ២០១៩ | ១ | ១ |
| ២ | លោក ងន សាំង | សមាជិក | ០៨ តុលា ២០១៩ | ១ | |
| ៣ | លោក Wiedmann Apiwat Christian | សមាជិក | ៣១ ឧសភា ២០២៣ | ១ | |

**តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម**

ក. ដើម្បីពិនិត្យឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្មនិងហានិភ័យ

ខ. ដើម្បីពិនិត្យឡើងវិញនូវការត្រួតពិនិត្យសវនកម្មផ្ទៃក្នុង និងសវនកម្មខាងក្រៅ

គ. ដើម្បីពិនិត្យ និងគ្រប់គ្រងដំណើរការគ្រប់គ្រងហានិភ័យរួមទាំងការកំណត់ហានិភ័យ និងការកាត់បន្ថយហានិភ័យ

ឃ. ធ្វើរបាយការណ៍ និងផ្តល់យោបល់ដល់ក្រុមប្រឹក្សាភិបាលលើបញ្ហាខាងលើ

ង. ដើម្បីឱ្យក្រុមហ៊ុន RMAC អាចផ្តល់ឲ្យភាគហ៊ុនិក និងស្ថាប័នដែលចាំបាច់ នូវការវាយតម្លៃប្រកបដោយតុល្យភាព និងច្បាស់លាស់អំពីជំហរ និងចក្ខុវិស័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុន RMAC

ច. ដើម្បីត្រួតពិនិត្យសវនកម្មផ្ទៃក្នុង និងគណៈគ្រប់គ្រងជាន់ខ្ពស់ដើម្បីធានាអះអាងថាពួកគេផ្តល់នូវការវាយតម្លៃតួនាទី និងចក្ខុវិស័យ និងរបាយការណ៍ប្រចាំខែស្តីពីតួនាទីនិងចក្ខុវិស័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុន RMAC ប្រកបដោយតុល្យភាព និងភាពសមស្រប

ឆ. ដើម្បីប្រាកដថាសវនកម្មផ្ទៃក្នុងត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ

ជ. ដើម្បីអនុវត្តដោយយកចិត្តទុកដាក់ជាមួយជំនាញ និងចាត់វិធានការដែលសមហេតុផលទាំងអស់ដើម្បីធានាបាននូវភាពត្រឹមត្រូវនៃការរាយការណ៍អំពីប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន RMAC និង

ឈ. ដើម្បីអនុវត្តសកម្មភាពផ្សេងៗតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល។

**លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម**

នៅឆ្នាំ ២០២៤ សមាជិកនៃគណៈកម្មាធិការមានការប្រជុំចំនួន ០១ នៅកាលបរិច្ឆេទតែមួយដូចគ្នានឹងការប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល។ សកម្មភាពខាងក្រោមនេះត្រូវបានធ្វើឡើងដោយគណៈកម្មាធិការៈ

- បានពិភាក្សា និងដោះស្រាយរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម។
- បានពិនិត្យឡើងវិញនូវផែនការសកម្មភាពនៃការអនុវត្តរបស់ ESMS (“គោលនយោបាយប្រព័ន្ធតាមដានបរិស្ថាននិងសង្គម”)។
- បានពិនិត្យ និង ពិភាក្សាពីរបាយការណ៍សវនកម្មផ្ទៃក្នុងរបស់ក្រុមហ៊ុន។

#### ១-២ គណៈកម្មាធិការតែងតាំង និងលាភការ

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក ITH Vichit | ប្រធានគណៈកម្មាធិការ | ០៨ តុលា ២០១៩ | ០១ | ០១ |
| ២ | លោក Kevin Robert Whitcraft | សមាជិក | ០៨ តុលា ២០១៩ | ០១ | |
| ៣ | លោក Thomas Arthur Whitcraft | សមាជិក | ០៨ តុលា ២០១៩ | ០១ | |

**តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការតែងតាំង និងលាភការ**

ក. ដើម្បីវាយតម្លៃ និងកំណត់នូវតម្រូវការ ភាពសមស្រប និងនីតិវិធីសម្រាប់ការតែងតាំងអភិបាល និងថ្នាក់ដឹកនាំជាន់ខ្ពស់។

ខ. ដើម្បីវាយតម្លៃការអនុវត្តរបស់អភិបាល និងថ្នាក់ដឹកនាំជាន់ខ្ពស់ និងធ្វើរបាយការណ៍ដូចគ្នាទៅក្រុមប្រឹក្សាភិបាល។

គ. ដើម្បីកំណត់ ពិនិត្យ និងផ្តល់ប្រាក់បំណាច់ និងលាភការសម្រាប់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់។

ឃ. ដើម្បីពិនិត្យ និងធ្វើតាមយន្តការ និងវាយតម្លៃលើការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល អភិបាល និងគណៈកម្មាធិការដទៃទៀតយ៉ាងតិចមួយដងក្នុងមួយឆ្នាំ។

ង. កាតព្វកិច្ចផ្សេងៗទៀតដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

**លទ្ធផលការងាររបស់គណៈកម្មាធិការតែងតាំង និងលាភការ**

នៅឆ្នាំ ២០២៤ សមាជិកនៃគណៈកម្មាធិការមានការប្រជុំចំនួន ០១ នៅកាលបរិច្ឆេទតែមួយដូចគ្នានឹងការប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល។ សកម្មភាពខាងក្រោមនេះត្រូវបានធ្វើឡើងដោយគណៈកម្មាធិការមានដូចជា៖

- បានពិភាក្សា និងពិនិត្យឡើងវិញនូវការផ្លាស់ប្តូរមន្ត្រីជាន់ខ្ពស់របស់ក្រុមហ៊ុន (ប្រធានគ្រប់គ្រងផ្នែកទូទៅនៅក្នុងផ្នែកខ្លះ)។

**គ. លាភការ ឬប្រាក់សំណងជម្ងឺចិត្ត**

**១- គោលនយោបាយសង្ខេបស្តីពីលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់**

ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាលត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាលខណៈពេលដែលប្រាក់បំណាច់ និងលាភការសម្រាប់បុគ្គលិកជាន់ខ្ពស់ត្រូវបានកំណត់តាមគោលការណ៍ធនធានមនុស្សរបស់ក្រុមហ៊ុន។

**២- អភិបាល និងក្រុមប្រឹក្សាភិបាល៖ បុគ្គលទទួលលាភការ ឬប្រាក់បំណាច់**

| ល.រ | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនលាភការ ឬប្រាក់បំណាច់ | ផ្សេងៗ |
|---|---|---|---|
| ១ | អភិបាល | ១៣៩.៨៥៣ ដុល្លាអាមេរិក | |
| ២ | បុគ្គលិកជាន់ខ្ពស់ | ១.៧៩៨.៣៨៥ ដុល្លាអាមេរិក | ១១១.៨៨៧ ដុល្លាអាមេរិក |
| ៣ | បុគ្គលិកដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥ រូប | ១.៦២៣.៦២៨ ដុល្លាអាមេរិក | |

**ឃ. ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិ**

| ល.រ | បរិយាយ | ដំណើរការនៃការវាយតម្លៃ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| ១ | ក្រុមប្រឹក្សាភិបាល | ការអនុវត្តរបស់ក្រុមប្រឹក្សាភិបាលត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយភាគហ៊ុនិក | • លទ្ធផលនៃការធ្វើអាជីវកម្ម<br>• ការចូលរួមប្រជុំក្រុមប្រឹក្សាភិបាល |

| | | | |
|---|---|---|---|
| ២ | អភិបាល | ការអនុវត្តរបស់អភិបាលត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយភាគហ៊ុនិក | • សមត្ថភាព និងលទ្ធផលនៃការអនុវត្ត<br>• ការចូលរួមក្នុងក្រុមប្រឹក្សាភិបាល និងការប្រជុំរបស់គណៈកម្មាធិការនានា។ |
| ៣ | គណៈកម្មាធិការ | ការអនុវត្តរបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាលត្រូវបានវាយតម្លៃដោយភាគហ៊ុនិក និងក្រុមប្រឹក្សាភិបាល | • លទ្ធផលនៃការ<br>• អនុវត្ត<br>• ការចូលរួមក្នុងក្រុមប្រឹក្សាភិបាល និងការប្រជុំរបស់គណៈកម្មាធិការនានា |
| ៤ | នាយកប្រតិបត្តិ | ការអនុវត្តនៃនាយកប្រតិបត្តិត្រូវបានវាយតម្លៃដោយក្រុមប្រឹក្សាភិបាល | • លទ្ធផលនៃការធ្វើអាជីវកម្ម<br>• ការកំណត់ជាមុននូវ KPI នៅក្នុងគោលនយោបាយធនធានមនុស្សរបស់ក្រុមហ៊ុនយើង |

**ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់**

នាយកប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់របស់យើងបានចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំដោយ គ.ម.ក និងការបណ្តុះបណ្តាលផ្សេងទៀតស្តីពីជំនាញគ្រប់គ្រងដែលរៀបចំដោយក្រុមហ៊ុនរបស់យើងខ្ញុំដូចជា៖

១. កិច្ចប្រជុំលើសេចក្តីព្រាងប្រកាសស្តីពី "ការបង្ហាញព័ត៌មាននិរន្តរភាព" នៅថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០២៤ ដែលរៀបចំដោយ និយ័តករមូលបត្រកម្ពុជា "SERC" ដោយមានការចូលរួមដោយមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃក្រុមហ៊ុន អ អិម អេ (ខេមូឌា) ម.ក។

២. កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងប្រកាសស្តីពី "ការបង្ហាញព័ត៌មានចីរភាព" នៅថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២៤ ដែលរៀបចំដោយ និយ័តករមូលបត្រកម្ពុ "SERC" ដោយមានការចូលរួមដោយមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃ ក្រុមហ៊ុន អ អិម អេ (ខេមូឌា) ម.ក។

៣. វគ្គបណ្តុះបណ្តាលស្តីពី "ការបង្ហាញព័ត៌មានចីរភាព" នៅថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤ ដែលរៀបចំដោយ និយ័តករមូលបត្រកម្ពុ "SERC" ដោយមានការចូលរួមដោយមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃ ក្រុមហ៊ុន អ អិម អេ (ខេមូឌា) ម.ក។

៤. សិក្ខាសាលាស្តីពី "ការដាក់ឱ្យដំណើរការសាកល្បងនូវប្រព័ន្ធបង្ហាញព័ត៌មានសាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ" នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០២៤ ដែលរៀបចំដោយ និយ័តករមូលបត្រកម្ពុ "SERC" ដោយមានការចូលរួមដោយមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃ ក្រុមហ៊ុន អ អិម អេ (ខេមូឌា) ម.ក។

៥. វគ្គបណ្ដុះបណ្ដាលស្ដីពី "ស្តង់ដារការបង្ហាញព័ត៌មាននិរន្តរភាព IFRD សម្រាប់អ្នករៀបចំសាជីវកម្ម" ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០២៤ ដែលរៀបចំដោយ ACMF និង ISSB ដោយមានការចូលរួមដោយប្រធាន ESMS នៃក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក។

៦. សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយ មាត្រា៦ នៃសៀវភៅណែនាំប្រតិបត្តិការនៅកម្ពុជា" នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយមានការចូលរួមពីមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក។

៧. សិក្ខាសាលាស្ដីពី "បច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា" ដែលធ្វើឡើងនៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០២៤ ដែលរៀបចំដោយ មជ្ឈមណ្ឌលកម្ពុជា 4.0 សហការជាមួយផ្សារមូលបត្រកម្ពុជា "CSX" និង សហភាពសហព័ន្ធយុវជនកម្ពុជា "សសយក" ដោយមានការចូលរួមពីមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក។

# ផ្នែកទី៣ - ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

**ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតៈ**

បេសកកម្មរបស់ក្រុមហ៊ុនរបស់យើងគឺ ដើម្បីបង្កើតតម្លៃប្រកបដោយចីរភាពសម្រាប់អតិថិជននិយោជិកនិងសហគមន៍និង សង្គមដែលយើងធ្វើប្រតិបត្តិការដោយផ្តល់ជូននូវដំណោះស្រាយផលិតផលនិងសេវាកម្មប្រកបដោយភាពច្នៃប្រឌិតនៅក្នុងបរិបទនៃក្រមសីលធម៌អាជីវកម្មល្អ។

ការធ្វើអាជីវកម្មប្រកបដោយភាពស្របច្បាប់និង ប្រកបដោយការទទួលខុសត្រូវនិងភាពស្មោះត្រង់គឺជាកត្តាចាំបាច់សម្រាប់ក្រុមហ៊ុនរបស់យើងជាពិសេស នាយកនិងមន្ត្រីជាន់ខ្ពស់របស់យើង។ យើងអាចបែងចែកក្រមធុរកិច្ចរបស់យើងទៅជាអន្តរកម្មសំខាន់បី។

**១. ក្រុមហ៊ុននិងច្បាប់**

ក្រុមហ៊ុនរបស់យើងប្តេជ្ញាអនុវត្តតាមច្បាប់និង បទបញ្ញត្តិគ្រប់ទីកន្លែងដែលវាធ្វើសកម្មភាពអាជីវកម្ម។ យើងរំពឹងថានាយកនិងនិយោជិកគ្រប់រូបត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយស្មោះត្រង់ស្មោះត្រង់និងគោរពតាមច្បាប់បទបញ្ញានិងគោលនយោបាយនិងនីតិវិធីរបស់ក្រុមហ៊ុន។ នៅពេលដែលច្បាប់ក្នុងប្រទេសមានតម្រូវការដែលខុសគ្នាពីបទប្បញ្ញត្តិនៃ ក្រមសីលធម៌និងគោលការណ៍ដូចខាងក្រោមតម្រូវការទាំងនោះមានសម្រាប់និយោជិកដែលធ្វើការនៅក្នុងប្រទេសទាំងនោះ។

**២. ក្រុមហ៊ុននិងនិយោជិក**

នាយកនិងនិយោជិកទាំងអស់ត្រូវតែធ្វើអ្វីៗដើម្បីផលប្រយោជន៍ក្រុមហ៊ុន។ ក្រុមហ៊ុនតម្រូវឱ្យនិយោជិកបង្ហាញរាល់ទំនាស់ផលប្រយោជន៍ដែលអាចកើតមានហើយចាត់វិធានការភ្លាមៗដើម្បីលុបបំបាត់ជម្លោះដែលបានកំណត់។ ទំនាស់ផលប្រយោជន៍កើតឡើងនៅពេលនិយោជិកមានទំនាក់ទំនងផ្ទាល់ខ្លួនចំណាប់ អារម្មណ៍ហិរញ្ញវត្ថុឬចំណាប់អារម្មណ៍ផ្សេងទៀតដែលអាចរំខានដល់ការវិនិច្ឆ័យនិងភារកិច្ចរបស់ពួកគេឬនៅពេលពួកគេប្រើតួនាទីរបស់ពួកគេនៅក្នុងក្រុមហ៊ុនដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។

ក្រុមហ៊ុនមិនអនុញ្ញាតឱ្យមានការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួនមិនត្រឹមត្រូវនោះទេ។ ការប្រើប្រាស់មិនត្រឹមត្រូវកើតឡើងនៅពេលដែល និយោជិកប្រើប្រាស់ទ្រព្យសម្បត្តិក្រុមហ៊ុនឬព័ត៌មានសម្រាប់ផលប្រយោជន៍ឬគុណប្រយោជន៍ផ្ទាល់ខ្លួនឬ សម្រាប់ផលប្រយោជន៍អ្នកដទៃនៅក្រៅក្រុមហ៊ុនដូចជាមិត្តភក្តិឬសមាជិកគ្រួសារ។ ការប្រើប្រាស់មិនត្រឹមត្រូវក៏កើតឡើងផងដែរនៅពេលទ្រព្យសម្បត្តិក្រុមហ៊ុនព័ត៌មានឬបច្ចេកវិទ្យាត្រូវបានប្រើប្រាស់សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនដែលមានកំណត់ឬដោយចៃដន្យឬប្រើប្រាស់ដោយរំលោភលើគោលការណ៍របស់ក្រុមហ៊ុនផ្សេងទៀត។

ព័ត៌មានសម្ងាត់របស់ក្រុមហ៊ុនគឺ ត្រូវការពារឱ្យបានសមរម្យគ្រប់ពេលវេលាហើយគួរត្រូវបានប្រើប្រាស់សម្រាប់គោលបំណងត្រឹមត្រូវរបស់វា។ ព័ត៌មានសម្ងាត់គឺជាព័ត៌មានដែលមានកម្មសិទ្ធិឬពាណិជ្ជកម្មដែលមានលក្ខណៈ ជាកម្មសិទ្ធិរបស់ក្រុមហ៊ុននិងព័ត៌មានឬទិន្នន័យផ្សេងទៀតដែលការបង្ហាញការបាត់បង់ឬប្រើប្រាស់ មិនត្រឹមត្រូវអាចជះឥទ្ធិពលអវិជ្ជមានដល់ក្រុមហ៊ុនភាពជោគជ័យនាពេលអនាគតឬទីតាំងប្រកួតប្រជែងរបស់ខ្លួន។ វារួមបញ្ចូលព័ត៌មានសម្ងាត់អំពីពាណិជ្ជកម្មនិងអាចរួមបញ្ចូលព័ត៌មានផ្សេងទៀតដែលក្រុមហ៊ុនបានប្រមូលបង្កើតឬទទួលបាន។ ព័ត៌មានសម្ងាត់ក៏រួមបញ្ចូលព័ត៌មានទាក់ទងនឹង ធុរកិច្ចរសើបដែលជាកម្មសិទ្ធិរបស់ភាគីទីបីរួមទាំងដៃគូក្រុមហ៊ុនអតិថិជននិងនិយោជិក។

**៣. ក្រុមហ៊ុននិងភាគីទីបីឬ តតីយជន**

អ្នកផ្គត់ផ្គង់គឺជាដៃគូដែលមានតម្លៃក្នុងជោគជ័យរបស់ក្រុមហ៊ុន។ អ្នកផ្គត់ផ្គង់ត្រូវបានជ្រើសរើសដោយផ្អែកលើតម្លៃសរុបរបស់ពួកគេដែលរួមមានគុណភាពសេវាកម្មបច្ចេកវិទ្យានិងតម្លៃ។ លក្ខខណ្ឌត្រូវបានទាក់ទងតាំងពីដំបូងក្នុងដំណើរការជ្រើសរើសអ្នកផ្គត់ផ្គង់។ កិច្ចព្រមព្រៀងចំពោះលក្ខខណ្ឌបែបនេះជាមួយនឹងការកែប្រែដែលអាចទទួលយកបានត្រូវបានឈានដល់មុនពេលចាប់ផ្តើមការងារ។

ផលិតផលនិងសេវាកម្មរបស់ក្រុមហ៊ុនជារឿយៗ ត្រូវបានទិញដោយអង្គភាពរដ្ឋាភិបាលសម្រាប់ប្រើប្រាស់ឬលក់បន្តទៅឱ្យអតិថិជនយោធាឬរដ្ឋាភិបាល។ ក្រុមហ៊ុនតម្រូវឱ្យមានការគោរពច្បាប់និងបទបញ្ញត្តិយ៉ាងតឹងរឹងដែលគ្រប់គ្រងការទិញទំនិញនិង សេវាកម្មដោយអង្គភាពរដ្ឋាភិបាលមិនថានៅសហរដ្ឋអាមេរិកឬនៅក្នុងប្រទេសណាមួយឡើយ។ វាជាគោលការណ៍របស់ក្រុមហ៊ុនដែលរាល់សេចក្តីថ្លែងការណ៍និងតំណាងឱ្យមន្ត្រីលទ្ធកម្មរបស់រដ្ឋាភិបាលគឺមានភាពត្រឹមត្រូវនិងការពិតរួមទាំងថ្លៃដើមនិងទិន្នន័យហិរញ្ញវត្ថុ។

ការស៊ីសំណូកពាណិជ្ជកម្មគឺខុស ច្បាប់និងត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌនៅក្នុងប្រទេសជាច្រើន។ រាល់ការទូទាត់ប្រាក់ផ្ទាល់ខ្លួនឬសំណូកដល់បុគ្គលដែលជួលដោយអតិថិជនឬអ្នកផ្គត់ផ្គង់របស់ក្រុមហ៊ុនឬការទទួលសំណូកឬការទូទាត់ផ្ទាល់ខ្លួនរបស់និយោជិករបស់ក្រុមហ៊ុនត្រូវហាមឃាត់យ៉ាងតឹងរ៉ឹង។ សូម្បីតែនៅក្នុងទីតាំងដែលសកម្មភាពបែបនេះអាចមិនមានបច្ចេកទេសនិយាយខុសច្បាប់ក៏ដោយវាត្រូវបានហាមឃាត់ជាដាច់ខាតដោយគោលការណ៍របស់ក្រុមហ៊ុន។

ក្រុមហ៊ុនហាមឃាត់ការបង់ប្រាក់មិនត្រឹមត្រូវដល់មន្ត្រីរដ្ឋាភិបាល។ ការបង់ប្រាក់មិនត្រឹមត្រូវគឺជាការទូទាត់ដោយផ្ទាល់ឬដោយប្រយោលមិនថាជាសាច់ប្រាក់ឬវត្ថុមានតម្លៃផ្សេងៗទៀត (ដូចជាការកម្សាន្តខ្ជិលច្រអូស) ដល់មន្ត្រីរដ្ឋាភិបាលឬគណបក្សនយោបាយក្នុងគោលបំណងជះឥទ្ធិពលដល់សកម្មភាពឬការសម្រេចចិត្តទទួលការព្យាបាលពិសេសឬផលប្រយោជន៍ផ្ទាល់ខ្លួនឬដើម្បីទទួលបាន ឬរក្សាអាជីវកម្ម។

ជាមួយនឹងអន្តរកម្មសំខាន់ទាំងបីនេះក្រមប្រតិបត្តិអាជីវកម្មរបស់យើងមានគោលការណ៍ផ្សេងទៀតដូចខាងក្រោម:

- ក្រមសីលធម៌អាជីវកម្មនិងវប្បធម៌វប្បធម៌សាជីវកម្ម
- គោលនយោបាយប្រឆាំងការសូកប៉ាន់និងប្រឆាំងអំពើពុករលួយ
- អំណោយបដិសណ្ឋារកិច្ចនិងការធ្វើដំណើរជាមួយគោលនយោបាយរបស់ភាគីទីបី
- គោលនយោបាយធ្វើដំណើរផ្ទៃក្នុង
- ការរក្សាការសម្ងាត់និងគោលនយោបាយការយកចិត្តទុកដាក់
- គោលនយោបាយទំនាស់ផលប្រយោជន៍
- គោលនយោបាយទ្រព្យសម្បត្តិក្រុមហ៊ុន
- គោលនយោបាយបរិស្ថាន
- គោលនយោបាយប្រតិបត្តិការអន្តរជាតិ
- កិច្ចសន្យារបស់រដ្ឋាភិបាលនិងគោលនយោបាយទំនាក់ទំនង
- គោលនយោបាយសុវត្ថិភាពនិងសុខភាពការងារ
- គោលនយោបាយសុវត្ថិភាពនិងសុវត្ថិភាពផលិតផល
- ការងារឱកាសស្មើគ្នានិងគោលនយោបាយគោរព
- គោលនយោបាយអ្នកនិយាយពីបញ្ហាដោយមិនបើកមុខ
- គោលនយោបាយគ្រប់គ្រងហានិភ័យ
- ទំនាក់ទំនងអតិថិជននិងគោលនយោបាយគុណភាពផលិតផល
- គោលនយោបាយជ្រើសរើសអ្នកផ្គត់ផ្គង់និងគោលនយោបាយភាគីទីបី
- គោលនយោបាយប្រឆាំងការលាងលុយកខ្វក់

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

ក្រមសីលធម៌អាជីវកម្មរបស់យើង អាចរកបានសម្រាប់និយោជិកទាំងអស់ដែលស្ថិតនៅក្នុងចំនុចរួមក្នុងស្រុករបស់យើង។ ក្រមសីលធម៌អាជីវកម្មនេះក៏ត្រូវបានផ្តល់ជូនសម្រាប់អ្នកផ្គត់ផ្គង់និងអ្នកម៉ៅការរងផងដែរ។ យន្តការដើម្បីបញ្ជ្រាបក្រមសីលធម៌របស់ក្រុមហ៊ុន ដល់ទៅអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ធ្វើឡើងតាមវិធីសាស្ត្រដូចខាងក្រោម៖

១. ផ្ដល់ឯកសារទាក់ទងនឹងក្រមសីលធម៌ដល់បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ដើម្បីពិនិត្យមើល និង យល់ព្រម ប្រតិបត្តិតាមក្រមសីលធម៌របស់ក្រុមហ៊ុន។

២. ក្រុមហ៊ុនតម្រូវឱ្យ បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ដែលជាចំនូលថ្មីទាំងអស់ឆ្លងកាត់វគ្គបណ្ដុះបណ្ដាលឱ្យយល់ដឹងពីក្រមសីលធម៌របស់ក្រុមហ៊ុនជាមុនសិន។ ការបណ្ដុះបណ្ដាលនោះធ្វើឡើងជាពីរដំណាក់៖ ដំណាក់កាលទី១ គឺការបណ្ដុះបណ្ដាលរួមក្នុងសាល (ឬអនឡាញ) ដោយមានការដឹកនាំពីផ្នែកស្រាវជ្រាវនិងបណ្ដុះ
បណ្ដាលរបស់ក្រុមហ៊ុន។ ដំណាក់កាលទី២ បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ត្រូវឆ្លងកាត់ការធ្វើតេសសាកល្បងពីការយល់ដឹងអំពីក្រមសីលធម៌របស់ក្រុមហ៊ុនតាមប្រព័ន្ធអេឡិចត្រូនិច ក្រោយការធ្វើតេសពួកគាត់នឹងទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សាមួយ។

៣. ផ្នែកស្រាវជ្រាវនិងបណ្ដុះបណ្ដាលរបស់ក្រុមហ៊ុន ក៏រៀបចំជាកម្មវិធីបណ្ដុះបណ្ដាលជាទៀតទាត់មួយ ដល់បុគ្គលិកជាន់ខ្ពស់ និងនិយោជិតទាំងអស់ដើម្បីពង្រឹកការយល់ដឹងពីក្រមសីលធម៌របស់ក្រុមហ៊ុន។

**គ. យន្តការ និងនិតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច**

ក្រុមហ៊ុនរបស់យើងទទួលបានការអនុវត្តក្រមសីលធម៌ការងារដោយវិធីសាស្ត្រពីរយ៉ាងគឺ៖

(១) ការរាយការណ៍អំពីការអនុវត្ត៖ ក្រុមហ៊ុន RMAC បានដាក់យន្តការដែលអនុញ្ញាតឲ្យបុគ្គលិករបស់យើងរាយការណ៍រាល់ការបំពានលើការអនុវត្តក្រមសីលធម៌។ ការរាយការណ៍អំពីភាពមិនប្រក្រតីនៃការអនុវត្តក្រមសីលធម៌អាចធ្វើឡើងតាមរយៈវិធីសាស្រដូចខាងក្រោម៖

១.១ ការរាយការណ៍តាមរយៈសារអេឡិចត្រូនិចមកកាន់ផ្នែកអនុលោកភាពរបស់ក្រុមហ៊ុន ឬ នៅលើគេហទំព័រផ្លូវការរបស់ក្រុមហ៊ុន

១.២. ការរាយការណ៍តាមរយៈការហៅមកកាន់ទូរស័ព្ទរបស់ក្រុមហ៊ុន (តាមប្រព័ន្ធ hotline)

១.៣ ការរាយការណ៍ដល់ប្រធានផ្នែកដែលនិយោជិតនីមួយៗធ្វើការ។

(២) ការត្រួតពិនិត្យដោយការអង្កេតផ្ទាល់៖ បន្ថែមលើការរាយការណ៍ ក្រុមហ៊ុនមានប្រធានគ្រប់គ្រងបរិស្ថាននិងសង្គម និងប្រធានផ្នែកសវនកម្មផ្ទៃដែលចុះទៅអង្កេតទីតាំងនីមួយៗរបស់ក្រុមហ៊ុនដើម្បីតាមដានការអនុវត្តក្រមសីលធម៌របស់ក្រុមហ៊ុន។

**ឃ. ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ**

**១- គោលនយោបាយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ សម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ**

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | មិនមាន |
| ២ | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | មិនមាន |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | មិនមាន |
| ៤ | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងច្រើនលើសលុប | មិនមាន |
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | មិនមាន |
| ៦ | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | មិនមាន |
| ៧ | ផ្សេងៗ | មិនមាន |

**២- ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ**

សម្រាប់ព័ត៌មានសម្អិតស្តីពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ សូមយោងតាមចំណុច ២៥ នៅក្នុងរបាយការណ៍សវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២៤ របស់យើង។

## ផ្នែកទី៤ - ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

### ក. សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ

ក្រុមហ៊ុនបានប្តេជ្ញារក្សាគ្រោងការណ៍ប្រតិបត្តិការគ្រប់គ្រងហានិភ័យដែលគាំទ្រដល់គោលដៅយុទ្ធសាស្ត្រ និងគោលបំណងនៃប្រតិបត្តិការដើម្បីធានាឱ្យមានការអនុលោមតាមតម្រូវការបទប្បញ្ញត្តិ និងបង្កប់នូវការអនុវត្តឧស្សាហកម្មល្អបំផុតក្នុងពិភពលោកសម្រាប់ប្រតិបត្តិការគ្រប់គ្រងហានិភ័យ។ គោលការណ៍នេះតម្រូវឱ្យមានការគ្រប់គ្រងហានិភ័យ ដើម្បីកំណត់ វាស់វែង តាមដាននិងគ្រប់គ្រងយុទ្ធសាស្ត្រ និងប្រតិបត្តិការហានិភ័យព្រមទាំងកាត់បន្ថយឱកាសនៃការបាត់បង់ដល់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវចំពោះ៖

- ការកើតឡើងនៃកម្រិតហានិភ័យអាចទទួលយកបាន ឬ ប្រភេទហានិភ័យនីមួយៗគឺសមល្ម
- ស្វែងយល់ពីហានិភ័យសំខាន់ៗដែលក្រុមហ៊ុនត្រូវប្រឈម
- ការធានាថាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវបានកើតឡើង និងបានថែរក្សាទុក
- គ្រោងការណ៍អនុម័ត គោលនយោបាយ និងនីតិវិធីពាក់ព័ន្ធនៃការគ្រប់គ្រងហានិភ័យ
- ការធានាថាគ្រោងការណ៍នេះអនុញ្ញាតឱ្យអ្នកគ្រប់គ្រងកំណត់ តាមដាន ត្រួតពិនិត្យ និងគ្រប់គ្រងលើហានិភ័យទាំងអស់
- ការធានាថាការគ្រប់គ្រងត្រូវបានអនុវត្តទៅតាមគ្រោងការណ៍
- ពិនិត្យឡើងវិញនូវរបាយការណ៍តាមកាលកំណត់លើបញ្ហាហានិភ័យនិងឆ្លើយតបតាមបញ្ហានោះ។

អ្នកគ្រប់គ្រងជាន់ខ្ពស់មានទំនួលខុសត្រូវចំពោះ៖

- ការរាយការណ៍ទៅក្រុមប្រឹក្សាភិបាលអំពីបញ្ហាហានិភ័យដែលពាក់ព័ន្ធ
- ការពិនិត្យមើលការអនុវត្តជារួមនៃគ្រោងការណ៍
- ការពិនិត្យឡើងវិញនូវព័ត៌មានដែលបានរាយការណ៍ពីគ្រោងការណ៍គ្រប់គ្រងហានិភ័យ និងធានាថាការអនុវត្តគឺសមស្របទៅនឹងការធ្វើឡើងដើម្បីគ្រប់គ្រងហានិភ័យ។

គណៈកម្មាធិការសវនកម្ម និងអនុវត្តមានទំនួលខុសត្រូវចំពោះ៖

- ការផ្តល់ការធានាថាហានិភ័យលើអាជីវកម្មសំខាន់ៗត្រូវបានគ្រប់គ្រងយ៉ាងត្រឹមត្រូវ
- ការផ្តល់ការធានាថាហានិភ័យត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ។
- ការផ្តល់ការធានាថាគ្រោងការណ៍គ្រប់គ្រងហានិភ័យកំពុងដំណើរការប្រកបដោយប្រសិទ្ធភាព។
- ការអនុម័តផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ និងរាល់ការផ្លាស់ប្តូរសំខាន់ៗចំពោះផែនការ
- ការពិនិត្យមើលប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង។
- ការត្រួតពិនិត្យការអភិវឌ្ឍ និងការអនុវត្តន៍សកម្មភាពគោរពតាមច្បាប់របស់ក្រុមហ៊ុន។

### ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

មុខងារសវនកម្មផ្ទៃក្នុងត្រូវបានផ្តល់ជូនដោយក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន RMAC។ ពេលវេលា និងកាលវិភាគសម្រាប់ការធ្វើសវនកម្មផ្ទៃក្នុងត្រូវអនុម័តដោយគណៈកម្មាធិការសវនកម្ម និងហានិភ័យ។ ការធ្វើសវនកម្មផ្ទៃក្នុងត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ដោយប្រព្រឹត្តទៅលើគ្រប់ផ្នែកទាំងអស់របស់ក្រុមហ៊ុនរួមមានផ្នែកហរិញ្ញវត្ថុ ផ្នែកច្បាប់ ផ្នែកធនធានមនុស្ស ផ្នែកប្រតិបត្តិការអាជីវកម្ម ផ្នែកបរិស្ថាននិងសង្គម ជាដើម។ ក្រុមការងារសវនកម្មផ្ទៃក្នុងនឹងត្រូវបញ្ជូលមកពីក្រុមហ៊ុនមេ RMA Group។ ជាគោលការណ៍ ក្រុមការងារសវនកម្មនឹងចាប់ផ្តើមការងាររបស់ខ្លួនក្នុងត្រីមាសទី៤នៃឆ្នាំនីមួយ ហើយនឹងបញ្ចប់របាយការណ៍របស់ខ្លួននៅត្រីមាសទី១នៃឆ្នាំបន្ទាប់។ របាយការណ៍នេះត្រូវដល់ជូនគណៈកម្មាធិការសវនកម្មនិងហានិយភ័យពិនិត្យ មុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលធ្វើការពិនិត្យ។ ការងារបន្ទាប់គឺក្រុមហ៊ុនធ្វើការកែលំអសកម្មភាពរបស់ខ្លួនតាមអនុសាសន៍ដែលលើកឡើងក្នុងរបាយការណ៍សវនកម្មផ្ទៃក្នុង។

**គ. ការធ្វើសវនកម្ម**

**១- សវនកម្មផ្ទៃក្នុង**

**១-១ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង**

ក. ធ្វើរបាយការណ៍សវនកម្មផ្ទៃក្នុងទាំងអស់ និងផ្តល់របាយការណ៍ទាំងនេះទៅគណៈកម្មាធិការសវនកម្ម និងហានិភ័យដើម្បីពិនិត្យ វាយតម្លៃ និងបញ្ជូនទៅឲ្យក្រុមប្រឹក្សាភិបាល

ខ. បញ្ជូនការរកឃើញសំខាន់ៗដែលអាចប៉ះពាល់ដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន RMAC ទៅកាន់គណៈកម្មាធិការសវនកម្ម និងហានិភ័យ ឬអភិបាលឯករាជ្យ

គ. រៀបចំការប្រជុំជាមួយគណៈកម្មាធិការសវនកម្ម និងហានិភ័យយ៉ាងតិចមួយដងក្នុងមួយឆ្នាំដោយមិនចាំបាច់មានវត្តមានរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់

ឃ. ធ្វើកាតព្វកិច្ចផ្សេងៗដែលបានចាត់ចែងដោយគណៈកម្មាធិការសវនកម្ម និងហានិភ័យ និងក្រុមប្រឹក្សាភិបាល និង

ង. កាតព្វកិច្ចផ្សេងៗដែលបានកំណត់ដោយគណៈកម្មាធិការសវនកម្ម និងហានិភ័យ និងក្រុមប្រឹក្សាភិបាល

**១-២ ការតែងតាំងថ្មី និងការដកហូត/ការលាលែងតំណែងរបស់ប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង**

នៅក្នុងឆ្នាំ២០២៤ មិនមានការផ្លាស់ប្តូរតំណែងរបស់ប្រធានសវនករផ្ទៃក្នុងទេ។

**២- សវនកម្មខាងក្រៅ**

| ល.រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទ ជ្រើសតាំង | តម្លៃសេវា សវនកម្ម | តម្លៃសេវាមិនមែន សវនកម្ម |
|---|---|---|---|---|
| ១ | Baker Tilly (Cambodia Co., Ltd | ១៥ វិច្ឆិកា ២០២៣ | | ១៦.៥០០ ដុល្លាអាមេរិក (ការពិនិត្យប្រចាំត្រីមាស) |
| ២ | Baker Tilly (Cambodia Co., Ltd | ០៧ តុលា ២០២៤ | ៣០.០០០ ដុល្លាអាមេរិក (សវនកម្មប្រចាំឆ្នាំ) | |

## ផ្នែកទី៥ - ភាគីពាក់ព័ន្ធ

### ក. បង្ហាញពីគោលការណ៍ និងសកម្មភាពទាក់ទងនឹងចំណុចខាងក្រោម៖

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ១ | សុខុមាលភាពរបស់អតិថិជន | ទំនាក់ទំនងអតិថិជន និង គោលការណ៍គុណភាពផលិតផល | ក្រុមហ៊ុន RMAC ប្តេជ្ញាផ្តល់ជូននូវផលិតផល និងសេវាកម្មដែលមានគុណភាពខ្ពស់បំផុតដល់អតិថិជនរបស់យើង។ ការពេញចិត្តរបស់អតិថិជន គឺជាគ្រឹះនៃអ្វីគ្រប់យ៉ាងដែលយើងធ្វើនៅក្រុមហ៊ុន RMAC។ សកម្មភាពគ្រប់គ្រងគុណភាពរបស់ RMAC ផ្តោតលើបទពិសោធន៍របស់អតិថិជនដែលជាអាទិភាពខ្ពស់បំផុតសម្រាប់ការរចនា និងកែតម្រូវឡើងវិញ។ |
| ២ | ការជ្រើសរើសអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ | ការជ្រើសរើសអ្នកផ្គត់ផ្គង់ និង គោលការណ៍ទំនាក់ទំនងភាគីទីបី | វាគឺជាគោលការណ៍របស់ក្រុមហ៊ុន RMAC ដើម្បីប្រាកដថាអ្នកផ្គត់ផ្គង់ ដៃគូរអាជីវកម្ម ឬភាគីទីបី៖<br>• ជៀសវាងជម្លោះផលប្រយោជន៍<br>• ជៀសវាងការគេងក្លែងបន្លំ និងការចំណាយមិនត្រឹមត្រូវ<br>• ធ្វើការដោយយកចិត្តទុកដាក់ជាមួយរដ្ឋាភិបាល<br>• ការពារព័ត៌មានបុគ្គល និងព័ត៌មានសម្ងាត់<br>• ប្រាកដថារបាយការណ៍ទាំងអស់គឺមានភាពស្មោះត្រង់ និងត្រឹមត្រូវពិតប្រាកដ<br>• ដឹង និងគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងបរិស្ថាន<br>• ប្រាកដថាគោលការណ៍របស់ក្រុមហ៊ុន RMAC គឺមិនធ្វើឲ្យខូចកិត្តិយសដោយសារអ្នកផ្គត់ផ្គង់ ឬសកម្មភាពអាជីវកម្មរបស់ដៃគូរ។ |
| ៣ | ការគ្រប់គ្រង និងការការពារនិយោជិត | ការងារ ឱកាសស្មើគ្នា និង គោលការណ៍ការគោរព | ក្រុមហ៊ុន RMAC បានប្តេជ្ញាផ្តល់ការងារដល់កម្លាំងពលកម្មចម្រុះនិងធ្វើការសំរេចចិត្តនិងសកម្មភាពទាក់ទងនឹងការងារដោយផ្អែកលើគុណសម្បត្តិនិងដោយមិនគិតពីពូជសាសន៍ សាសនា ពណ៌សម្បុរ ភេទ (រួមទាំងការមានផ្ទៃពោះ) សញ្ជាតិ/ជនជាតិ ស្ថានភាពសញ្ជាតិ អាយុ លក្ខណ:ហ្សែន ចំណង់ផ្លូវភេទ ពិការភាព |

| | | | |
|---|---|---|---|
| | | | ផ្លូវចិត្ត ឬរាងកាយ ឬលក្ខណៈណាមួយដែលអាចត្រូវបានការពារដោយច្បាប់។ |
| ៤ | ការគាំពារបរិស្ថាន | គោលការណ៍បរិស្ថាន | ក្រុមហ៊ុន RMAC បានគោរពតាមច្បាប់ បទប្បញ្ញត្តិ គោលការណ៍ និងគោលដៅពាក់ព័ន្ធទាំងអស់ដែលពាក់ព័ន្ធនឹងសុខុមាលភាពបរិស្ថាន។ ក្រុមហ៊ុន RMAC បានអភិវឌ្ឍន៍ឥតឈប់ឈរនិងកែលម្អប្រព័ន្ធខាងក្នុងសម្រាប់និរន្តរភាពបរិស្ថាន។ ក្រុមហ៊ុន RMAC លើកទឹកចិត្តនិងចូលរួមក្នុងកម្មវិធីបរិស្ថានដោយមានសហប្រតិបត្តិការជាមួយដៃគូអាជីវកម្ម និងអតិថិជននៅពេលណាដែលអាចធ្វើទៅបាន។ |
| ៥ | កម្មវិធីប្រឆាំងអំពើពុករលួយ | គោលការណ៍ប្រឆាំងការស៊ីសំណូក និងអំពើពុករលួយ | គោលការណ៍នេះផ្តោតទៅលើតម្រូវការរបស់ក្រុមហ៊ុន RMAC នៅក្នុងការប្រឆាំងទៅនឹងសកម្មភាព ឥរិយាបទ និងលទ្ធផលនៃការស៊ីសំណូក និង អំពើពុករលួយ។ |

ខ. ពិពណ៌នាអំពីទំនួលខុសត្រូវសង្គមរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

| ល.រ | អ្នកទទួលផលប្រយោជន៍ | ទំហំនៃការបរិច្ចាគ | គោលបំណងនៃការបរិច្ចាគ |
|---|---|---|---|
| ១ | រដ្ឋបាលខេត្តកំពត | ១០.៦០០ ដុល្លារ | បានបរិច្ចាគកៅអីចំនួន ៣០ កៅអី ដើម្បីដាក់នៅជុំវិញទីធ្លាសាធារណៈនៃឧទ្យានដងព្រែក សម្រាប់ផ្តល់នូវកន្លែងសម្រាក និងលំហែកាយកាន់តែងាយស្រួលដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍ដែលរស់នៅឬលេងកម្សាន្តនៅទីនោះ។ |
| ២ | សាលាបឋមសិក្សាក្រពុំឈូក ខេត្តតាកែវ | ៣.០០០ ដុល្លារ | សាងសង់បង្គន់អនាម័យចំនួន០១ខ្នងដែលមាន៤បន្ទប់សម្រាប់សិស្សបឋមសិក្សានៅខេត្តតាកែវ ។ |
| ៣ | រដ្ឋបាលខេត្តកំពង់ស្ពឺ | ៧០០ ដុល្លារ | ដើម្បីលើកទឹកចិត្តឱ្យមានការអនុវត្តការគ្រប់គ្រងសំរាមឱ្យបានត្រឹមត្រូវ និងរួមចំណែកធ្វើឱ្យមានបរិស្ថានស្អាត និងមាននិរន្តរភាពបន្ថែមទៀតនៅក្នុងខេត្តកំពង់ស្ពឺ។ |
| ៤ | រដ្ឋបាលស្រុកទឹកឈូ និងសិស្សានុសិស្ស ខេត្តកំពត | ២.៤០០ ដុល្លារ | ដើម្បីផ្តល់ជូនសិស្សានុសិស្សក្រីក្រនូវមធ្យោបាយធ្វើដំណើរប្រកបដោយសុវត្ថិភាព និងលើកកម្ពស់ទេសចរណ៍នៅក្នុងស្រុកទឹកឈូ។ |
| ៥ | ឃុំអន្លង់ត្នោត ខេត្តពោធិ៍សាត់ | ៥.៥៧៥ ដុល្លារ | បរិច្ចាគ និងដាំកូនឈើជាង ១០០០ដើម នៅតាមចិញ្ចើមផ្លូវ និងផ្លូវនានាក្នុងឃុំ/សង្កាត់ ដើម្បីបង្កើនសោភ័ណភាព ជីវៈចម្រុះ និងបង្កើនគម្របបៃតងក្នុងខេត្តពោធិ៍សាត់។ |
| ៦ | កីឡាវាយកូនបាល់កម្ពុជា | ១០.០០០ ដុល្លារ | បានគាំទ្រដល់ព្រឹត្តិការណ៍កីឡាវាយកូនបាល់អន្តរជាតិ "2024 Davis Cup Asia/Oceania Group IV" នៅកម្ពុជា ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍកីឡាវាយកូនបាល់ និងកីឡាផ្សេងទៀត និងលើកទឹកចិត្តដល់អត្តពលិកក្នុងស្រុក ក៏ដូចជាលើកកម្ពស់សុខុមាលភាព។ |
| ៧ | មន្ទីរពេទ្យគន្ធបុប្ផា | ៧០០ ដុល្លារ | រៃអង្គាសប្រាក់បានប្រមាណចំនួន ៦.៨៨៧ ដុល្លារ តាមរយៈការរត់ប្រណាំងសប្បុរសធម៌ និងបរិច្ចាគដល់មន្ទីរពេទ្យគន្ធបុប្ផាក្នុងខេត្តសៀមរាប ដើម្បីគាំទ្រដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់មន្ទីរពេទ្យ ក្នុងការផ្តល់ការថែទាំសុខភាពប្រកបដោយគុណភាពដល់កុមារកម្ពុជា។ |
| ៨ | ខេត្តសៀមរាប | ២៤.៥០០ ដុល្លារ | ដាំកូនឈើចំនួន ១.៣៥០ដើម នៅតាមបណ្តោយផ្លូវជាតិលេខ៦ ដល់រង្វង់មូលព្រះបាទជ័យវរ្ម័នទី៧ ដើម្បីបង្កើនទេសភាពបៃតងនៃខេត្តសៀមរាប និងរួមចំណែកលើកកម្ពស់សោភ័ណភាព និងបរិស្ថានខេត្តសៀមរាប។ |
| ៩ | រដ្ឋបាលខេត្តត្បូងឃ្មុំ | ៨.២០០ ដុល្លារ | បានផ្តល់ធុងសំរាមចំនួន ៦៦ និងកៅអីចំនួន ១៦ ដល់រដ្ឋបាលខេត្តត្បូងឃ្មុំ សម្រាប់ដាក់នៅតាមដងទន្លេសិប្បនិមិត្ត និងសាលាខេត្ត ដើម្បីរួមចំណែកក្នុងការធ្វើឱ្យបរិស្ថានកាន់តែស្អាត និងកាន់តែមានផាសុកភាពសម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។ |

| | | | |
|---|---|---|---|
| ១០ | មន្ទីរពេទ្យកុមារអង្គរ | ៥០០ ដុល្លារ | បានគាំទ្រដល់ព្រឹត្តិការណ៍ជិះកង់វែអង្គាសប្រាក់របស់មន្ទីរពេទ្យកុមារអង្គរ។ |
| ១១ | សហគមន៍អេកូទេសចរណ៍ត្រពាំងសង្កែ ខេត្តកំពត | ១០០ ដុល្លារ | ដាំដើមកោងកាងចំនួន ១០០ ដើម ដើម្បីលើកកម្ពស់ការយល់ដឹងអំពីតួនាទីរបស់ព្រៃកោងកាង លើកកម្ពស់ជីវចម្រុះ និងគាំទ្រសហគមន៍អេកូទេសចរណ៍។ |
| ១២ | ផ្នែកបរិក្ខារកសិកម្ម(AED ) អ្នកបរិច្ចាគឈាមទូទាំងប្រទេស | 0 ដុល្លារ | បរិច្ចាគឈាមដល់មន្ទីរពេទ្យគន្ធបុប្ផា ក្នុងរាជធានីភ្នំពេញ និងមណ្ឌលសុខភាពតាមបណ្ដាខេត្តនានា ដើម្បីទ្រទ្រង់ប្រតិបត្តិការប្រចាំថ្ងៃ និងផ្ដល់ការថែទាំសុខភាពសំខាន់ៗ ដើម្បីជួយសង្គ្រោះកុមារ និងប្រជាជនកម្ពុជា។ |
| ១៣ | ផ្នែករថយន្ត Ford (Ford Adventure 2024) | ១៦.០០០ ដុល្លារ | ឧបត្ថម្ភគ្រឿងឧបភោគបរិភោគសំខាន់ៗ ដល់ប្រជាពលរដ្ឋក្រីក្រចំនួន ៨០០គ្រួសារ ក្នុងខេត្តស្ទឹងត្រែង។ គ្រួសារនីមួយៗទទួលបានសម្ភារចាំបាច់សម្រាប់ ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ រួមមាន មី ទឹកត្រី មុង ភួយ និងអង្ករ ២៥គីឡូក្រាម រួមទាំងសម្ភារៈប្រើប្រាស់មួយចំនួនទៀត។ |
| ១៤ | ព្រឹទ្ធាចារ្យនៅខេត្តតាកែវ | ៧៦៩ ដុល្លារ | ផ្ដល់ជូនកញ្ចប់អំណោយដល់ចាស់ជរាក្នុងខេត្តតាកែវសម្រាប់ទទួលទានប្រចាំថ្ងៃ។ |

## ផ្នែកទី៦ - ការបង្ហាញព័ត៌មាន និងតម្លាភាព

### ក. បង្ហាញអំពីព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

| ល.រ | ព័ត៌មាន | មាន/គ្មានបង្ហាញ |
|---|---|---|
| ១ | ចក្ខុវិស័យ/ បេសកកម្ម/ គោលដៅអាជីវកម្ម | មាន |
| ២ | សូចនាករហិរញ្ញវត្ថុ | មាន |
| ៣ | សូចនាករមិនមែនហិរញ្ញវត្ថុ | មាន |
| ៤ | កត្តាហានិភ័យសំខាន់ៗ | មាន |
| ៥ | គោលនយោបាយភាគលាភ | មាន |
| ៦ | ជីវប្រវត្តិរបស់អភិបាល | មាន |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | មាន |
| ៨ | ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មាន |

**បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបញ្ជាក់ពីមូលហេតុ ប្រសិនបើមិនបានបង្ហាញព័ត៌មានខាងលើ*

### ខ. ពិពណ៌នាអំពីយន្តការនៃការបង្ហាញព័ត៌មាន ដោយរៀបរាប់ពីមធ្យោបាយ និតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក បានតែងតាំងបុគ្គលដូចខាងក្រោមដើម្បីត្រួតពិនិត្យការផ្សព្វផ្សាយ៖
១. បុគ្គលិកទទួលបន្ទុកផ្តល់ពត៌មាន៖ **លោក ងន សាំង**; តំណែង: នាយកប្រតិបត្តិ
២. ជំនួយការបុគ្គលិកទទួលបន្ទុកផ្តល់ពត៌មាន៖ **លោក មាស សុវណ្ណ**; តំណែង: អ្នកគ្រប់គ្រងផ្នែកច្បាប់ និងអនុវត្ត

### គ. ទំនាក់ទំនងជាមួយវិនិយោគិន

#### ១- បង្ហាញពីយន្តការ និងវីតិវិធីនៃការទំនាក់ទំនងជាមួយវិនិយោគិន

ក្រុមហ៊ុនរបស់យើងផ្សព្វផ្សាយព័ត៌មានដែលចាំបាច់ចំពោះសកម្មភាព និងលទ្ធផលហិរញ្ញវត្ថុនៅលើគេហទំព័រ CSX និងគេហទំព័រផ្លូវការរបស់យើង: https://www.cambodia.rmagroup.net/about-us/investor-relations/

#### ២- ពិពណ៌នាដោយសង្ខេបអំពីទំនាក់ទំនងជាមួយនឹងវិនិយោគិនក្នុងរយៈពេល ១ ឆ្នាំចុងក្រោយ

ក្រុមហ៊ុនតែងតែព្យាយាមរក្សាទំនាក់ទំនងល្អជាមួយវិនិយោគិនរបស់យើង។ យើងបានបង្កើតព័ត៌មានចាំបាច់ទាំងអស់ទាក់ទងនឹង អាជីវកម្មរបស់ក្រុមហ៊ុនយើងនៅលើគេហទំព័រផ្លូវការផងដែរ។ សំខាន់ជាងនេះទៅទៀតក្រុមហ៊ុន RMAC បានប្រាស្រ័យទាក់ទងជាមួយវិនិយោគិនរបស់យើងដើម្បីឆ្លើយតបរាល់សំណួរតាមអ្វីដែលយើងអាចធ្វើទៅបាន។ យើងក៏រក្សាអ្នកវិនិយោគរបស់យើងធ្វើបច្ចុប្បន្នភាពសម្រាប់ការទូទាត់ការប្រាក់ និងប្រាក់ដើមលើមូលបត្របំណុលរបស់ក្រុមហ៊ុនយើងផងដែរ។ ឧទាហរណ៍ យើងបានបង្ហាញទាន់ពេលវេលានូវការប្រាក់ និងការទូទាត់ប្រាក់ដើមរបស់យើងសម្រាប់ឆ្នាំ២០២៤ ដល់ទីផ្សារមូលបត្រកម្ពុជានិងនិយ័តករមូលបត្រកម្ពុជាដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ។